**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២៦-២០៤.ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់សន្ទនីយភាពចាំបាច់
# ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការតែងតាំង លោកជំទាវ **ជា សិរី** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦

## សម្រេច

### ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងបង្កើតក្របខ័ណ្ឌក្នុងការផ្តល់សន្ទនីយភាពចាំបាច់ជាជម្រើសចុងក្រោយចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលកំពុងជួបបញ្ហាសន្ទនីយភាពបណ្តោះអាសន្ន ក្នុងគោលដៅទប់ស្កាត់ហានិភ័យជាប្រព័ន្ធ និងរក្សាស្ថិរភាពហិរញ្ញវត្ថុ។

### ប្រការ ២.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា តទៅនេះហៅថា "គ្រឹះស្ថាន"។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

## ប្រការ ៣.- និយមន័យ

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ការផ្តល់សន្ទនីយភាពចាំបាច់** (Emergency Liquidity Assistance - ELA) សំដៅដល់ការផ្តល់បន្ទាត់ឥណទានដែលមានទ្រព្យធានា ភ្ជាប់ជាមួយគណនីចរន្តដែលគ្រឹះស្ថានបានបើកនៅធនាគារជាតិនៃកម្ពុជា។ បន្ទាត់ឥណទាននេះត្រូវបានផ្តល់ដោយឆន្ទានុសិទ្ធិរបស់ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអ្នកឱ្យខ្ចីចុងក្រោយ (Lender of Last Resort) ចំពោះគ្រឹះស្ថានដែលធនាគារជាតិនៃកម្ពុជាបានវាយតម្លៃថាមានសាធនភាព និងនៅបន្តដំណើរការអាជីវកម្មជាប្រក្រតី ប៉ុន្តែកំពុងជួបបញ្ហាកង្វះសន្ទនីយភាពបណ្តោះអាសន្ន។
- **ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី** (Marginal Lending Facility - MLF) សំដៅដល់ហ្វាស៊ីលីធីជាប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា ដែលមានរយៈពេល ១ (មួយ) យប់ (Overnight) និងមានទ្រព្យធានា ដើម្បីសម្រួលដល់ការគ្រប់គ្រងសន្ទនីយភាពរយៈពេលខ្លីរបស់គ្រឹះស្ថាន។
- **អត្រា SOFR** សំដៅដល់អត្រាការប្រាក់យោងជាប្រាក់ដុល្លារអាមេរិក ដែលមានឥណប្រតិទាន ៦ (ប្រាំមួយ) ខែ ដែលធនាគារជាតិនៃកម្ពុជាប្រើប្រាស់ក្នុងការទូទាត់ការប្រាក់ដល់គ្រឹះស្ថាន។

## ប្រការ ៤.- ស្ថានភាពរបស់គ្រឹះស្ថាន

គ្រឹះស្ថានដែលស្នើសុំសន្ទនីយភាពចាំបាច់ ត្រូវមានស្ថានភាព ដូចខាងក្រោម៖

- មានសាធនភាព៖ គ្រឹះស្ថានត្រូវបានវាយតម្លៃថាមានសាធនភាព លុះត្រាតែមានអនុបាតភាពគ្រប់គ្រាន់នៃដើមទុនយ៉ាងហោចណាស់ស្មើ ឬលើសកម្រិតអប្បបរមា ក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ ចុងក្រោយ និងបង្ហាញថា អាចមានអនុបាតភាពគ្រប់គ្រាន់នៃដើមទុនស្មើ ឬលើសកម្រិតអប្បបរមា ក្នុងរយៈពេល ៣ (បី) ខែ ខាងមុខ
- នៅបន្តដំណើរការអាជីវកម្មជាប្រក្រតី៖ គ្រឹះស្ថានត្រូវបានវាយតម្លៃថាអាចនៅបន្តដំណើរការអាជីវកម្មជាប្រក្រតី ប្រសិនបើគ្រឹះស្ថានមានប្រាក់ចំណេញរយៈពេល ៣ (បី) ឆ្នាំ ចុងក្រោយ និង
- មានទ្រព្យធានាដែលអាចទទួលយកបាន៖ គ្រឹះស្ថានត្រូវមានទ្រព្យធានាដែលអាចទទួលយកបានគ្រប់គ្រាន់បន្ទាប់ពីដកហ៊ែខាត់ និងមិនជាប់កាតព្វកិច្ច ដូចបានកំណត់ក្នុងប្រការ ៧ នៃប្រកាសនេះ។

ធនាគារជាតិនៃកម្ពុជាអាចផ្តល់សន្ទនីយភាពចាំបាច់ បន្ទាប់ពីគ្រឹះស្ថានបានប្រើប្រាស់ជិតអស់ ឬអស់លទ្ធភាពនូវជម្រើសប្រភពទុនរយៈពេលខ្លីផ្សេងៗទៀត ដូចជា មូលនិធិពីទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ មូលនិធិរបស់គ្រុប និងហ្វាស៊ីលីធីផ្សេងទៀតរបស់ធនាគារជាតិនៃកម្ពុជា ជាដើម។

ចំពោះគ្រឹះស្ថានជាបុត្តសម្ព័ន្ធធនាគារបរទេស ឬសាខាធនាគារបរទេស គ្រឹះស្ថានត្រូវស្នើសុំការគាំទ្រពីក្រុមហ៊ុនមេ និង/ឬ ភាគទុនិកឱ្យអស់លទ្ធភាពជាមុនសិន មុននឹងស្នើសុំសន្ទនីយភាពចាំបាច់ពីធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជា មានឆន្ទានុសិទ្ធិក្នុងការសម្រេចលើសំណើសុំសន្ទនីយភាពចាំបាច់របស់គ្រឹះស្ថាន ដោយផ្អែកលើការវាយតម្លៃសូចនាករ និង/ឬ លក្ខខណ្ឌផ្សេងទៀត តាមករណី

ជាក់ស្តែង។ ទោះបីជាធនាគារជាតិនៃកម្ពុជា បានសម្រេចផ្តល់សន្ទនីយភាពចាំបាច់ដល់គ្រឹះស្ថានក៏ដោយ ធនាគារជាតិនៃកម្ពុជារក្សាសិទ្ធិក្នុងការមិនបញ្ចេញសាច់ប្រាក់ប្រសិនបើពិនិត្យឃើញថាគ្រឹះស្ថាននៅមានលទ្ធភាពប្រើប្រាស់ជម្រើសមូលនិធិរយៈពេលខ្លីផ្សេងៗទៀត។

## ប្រការ ៥.- ការស្នើសុំសន្ទនីយភាពចាំបាច់

គ្រឹះស្ថានត្រូវរៀបចំលិខិតស្នើសុំសន្ទនីយភាពចាំបាច់ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- ផែនការទុនក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ ខាងមុខ ដើម្បីបញ្ជាក់ពីតម្រូវការអតិបរមា និងការប្រើប្រាស់សន្ទនីយភាពចាំបាច់
- របាយការណ៍ប្រចាំថ្ងៃស្តីពី លំហូរសាច់ប្រាក់ចេញ-ចូល
- របាយការណ៍ព្យាករលំហូរសន្ទនីយភាពសុទ្ធសម្រាប់រយៈពេល ១៤ (ដប់បួន) ថ្ងៃខាងមុខ
- របាយការណ៍វាយតម្លៃស្ថានភាពរួមរបស់គ្រឹះស្ថានដើម្បីបង្ហាញថាគ្រឹះស្ថានមានសាធនភាព និងនៅបន្តដំណើរការអាជីវកម្មជាប្រក្រតី ដូចមានកំណត់ក្នុងប្រការ ៤ នៃប្រកាសនេះ
- ប្រភេទ និងតម្លៃទ្រព្យធានាដែលអាចទទួលយកបាន
- ការវិវត្តនៃស្ថានភាពសន្ទនីយភាពចាប់តាំងពីពេលគ្រឹះស្ថានជួបបញ្ហាសន្ទនីយភាពរហូតដល់ថ្ងៃស្នើសុំសន្ទនីយភាពចាំបាច់ ដោយមានបង្ហាញពីឫសគល់នៃបញ្ហាសន្ទនីយភាព និងវិធានការដែលបានអនុវត្តរួចហើយ
- របាយការណ៍អនុបាតគ្របខណ្ឌសន្ទនីយភាពនៅថ្ងៃស្នើសុំសន្ទនីយភាពចាំបាច់ និង
- ផែនការសកម្មភាពច្បាស់លាស់ក្នុងការដោះស្រាយកង្វះសន្ទនីយភាពដោយត្រូវព្យាករដោយប្រុងប្រយ័ត្នអំពីពេលវេលាច្បាស់លាស់សម្រាប់អនុវត្តផែនការសកម្មភាព និងទូទាត់សងមកវិញនូវសន្ទនីយភាពចាំបាច់។

ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យគ្រឹះស្ថានផ្តល់ព័ត៌មាន ឬទិន្នន័យបន្ថែមទៀតពីគ្រឹះស្ថាន ភាគទុនិក ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ សវនករផ្ទៃក្នុង សវនករឯករាជ្យ បុគ្គល ឬភាគីពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។

## ប្រការ ៦.- លក្ខខណ្ឌកំណត់នៃការផ្តល់សន្ទនីយភាពចាំបាច់

លក្ខខណ្ឌកំណត់ក្នុងការផ្តល់សន្ទនីយភាពចាំបាច់ មានដូចខាងក្រោម៖

១/- សន្ទនីយភាពចាំបាច់អាចផ្តល់ជាប្រាក់រៀល និង/ឬ ប្រាក់ដុល្លារអាមេរិក ដោយផ្អែកលើការស្នើសុំ និងតម្រូវការរបស់គ្រឹះស្ថាន ដោយមានបញ្ជាក់ក្នុងផែនការទុន

២/- ទំហំសន្ទនីយភាពចាំបាច់អតិបរមាដែលផ្តល់ដល់គ្រឹះស្ថាន មិនត្រូវលើសពីតម្រូវការដែលបានព្យាកររបស់គ្រឹះស្ថាន និងតម្លៃទ្រព្យធានាបន្ទាប់ពីដកហ៊ែខាត់

៣/- ការផ្តល់សន្ទនីយភាពចាំបាច់មានរយៈពេលដំបូង ៦ (ប្រាំមួយ) ខែ និងអាចពន្យារពេលបានយ៉ាងយូរត្រឹម ៦ (ប្រាំមួយ) ខែ ម្តងទៀត តាមតម្រូវការជាក់ស្តែង ទំហំទ្រព្យធានាគ្រប់គ្រាន់ ការវាយតម្លៃរបស់ធនាគារជាតិនៃកម្ពុជា និងការអនុវត្តតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យាស្តីពី ការផ្តល់សន្ទនីយភាពចាំបាច់

៤/- អត្រាការប្រាក់សម្រាប់ការផ្តល់សន្ទនីយភាពចាំបាច់ត្រូវបានកំណត់ ដូចខាងក្រោម៖

- អត្រាការប្រាក់សន្ទនីយភាពចាំបាច់ជាប្រាក់រៀលប្រចាំឆ្នាំ ត្រូវកំណត់យកអត្រាការប្រាក់ MLF + ២%
- អត្រាការប្រាក់សន្ទនីយភាពចាំបាច់ជាប្រាក់ដុល្លារអាមេរិកប្រចាំឆ្នាំ ត្រូវកំណត់យកអត្រាអតិបរមារវាងអត្រាការប្រាក់ MLF + ៤% និង SOFR + ៤% និង
- ការប្រាក់នឹងត្រូវគិតលើមូលដ្ឋានបង្គរប្រចាំថ្ងៃចាប់ពីថ្ងៃទទួលបានសន្ទនីយភាពចាំបាច់តាមទំហំទឹកប្រាក់ដែលបានប្រើប្រាស់ និងចំនួនថ្ងៃជាក់ស្តែងក្នុងឆ្នាំនីមួយៗ និងត្រូវទូទាត់សងនៅរៀងរាល់ ១៤ (ដប់បួន) ថ្ងៃ ម្តង និង

៥/- គ្រឹះស្ថានអាចទូទាត់សងផ្នែកខ្លះ ឬទាំងស្រុងនៃសន្ទនីយភាពចាំបាច់មុនឥណប្រតិទាន។ ក្នុងករណីគ្រឹះស្ថានមិនបានទូទាត់សងសន្ទនីយភាពចាំបាច់តាមកាលកំណត់ ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តអត្រាការប្រាក់ពិន័យរហូតដល់ពីរដងនៃអត្រាការប្រាក់ដូចមានកំណត់ក្នុងចំណុច ៤ នៃប្រការនេះ ទៅលើប្រាក់ដើមរហូតដល់មានការទូទាត់សងទាំងស្រុង និង/ឬ ចាត់វិធានការដទៃទៀតតាមច្បាប់ជាធរមាន។

ទន្ទឹមនេះ គ្រឹះស្ថានត្រូវចុះកិច្ចសន្យាស្តីពី ការផ្តល់សន្ទនីយភាពចាំបាច់ ជាមួយធនាគារជាតិនៃកម្ពុជាជាមុន ដើម្បីទទួលបានសន្ទនីយភាពចាំបាច់។

**ប្រការ ៧.- ទ្រព្យធានា**

ទ្រព្យធានាដែលអាចទទួលយកបាន សម្រាប់ការផ្តល់សន្ទនីយភាពចាំបាច់ មានលំដាប់អាទិភាព ដូចខាងក្រោម៖

- មូលបត្ររដ្ឋ និង
- ទ្រព្យសកម្មផ្សេងៗ ដែលនឹងកំណត់ដោយធនាគារជាតិនៃកម្ពុជា។

ទ្រព្យធានាដែលអាចទទួលយកបានខាងលើ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

១/- អាចអនុវត្តសិទ្ធិតាមផ្លូវច្បាប់ ដូចជា៖

- ជាទ្រព្យ និង/ឬ កម្មសិទ្ធិផ្ទាល់របស់គ្រឹះស្ថាន
- មិនជាប់កាតព្វកិច្ច និង/ឬ មិនមែនជាកម្មវត្ថុនៃការអនុវត្តនីតិវិធីដោយបង្ខំ
- អាចផ្ទេរដោយស្របច្បាប់ និងអាចរក្សាទុកសម្រាប់ធានាកាតព្វកិច្ច ចំពោះធនាគារជាតិនៃកម្ពុជា និង

២/- មានឥណប្រតិទាននៅសល់ស្មើ ឬវែងជាងឥណប្រតិទានរបស់សន្ទនីយភាពចាំបាច់។

គ្រឹះស្ថានត្រូវផ្តល់បញ្ជីទ្រព្យសកម្មដែលបំពេញលក្ខខណ្ឌខាងលើសម្រាប់ប្រើជាទ្រព្យធានាក្នុងការស្នើសុំសន្ទនីយភាពចាំបាច់ជូនធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជានឹងកំណត់ចំនួនទ្រព្យធានា និងជ្រើសរើសទ្រព្យសកម្មដែលត្រូវដាក់ធានាសម្រាប់ទំហំសន្ទនីយភាពចាំបាច់សរុប។ តម្លៃនៃទ្រព្យធានាសរុបបន្ទាប់ពីដកហ៊ៃខាត់ ត្រូវលើសពីចំនួនសន្ទនីយភាពចាំបាច់ដែលស្នើសុំរួមបញ្ចូលទាំងការប្រាក់ដែលត្រូវទូទាត់មកធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានត្រូវធ្វើបច្ចុប្បន្នភាពចំពោះទ្រព្យធានា នៅពេលដែលស្ថានភាពទ្រព្យធានាត្រូវបានវាយតម្លៃថាមានការប្រែប្រួល រួមមានការធ្លាក់ចុះតម្លៃ ឬការប្រែប្រួលចំណាត់ថ្នាក់ តាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា។ ក្នុងករណីដែលគ្រឹះស្ថានស្នើសុំសន្ទនីយភាពចាំបាច់បន្ថែម គ្រឹះស្ថានត្រូវដាក់ទ្រព្យធានាបន្ថែម។

**ប្រការ ៨.- ហានិភ័យលើទ្រព្យធានា**

ធនាគារជាតិនៃកម្ពុជា នឹងកំណត់ហៃខាត់ចំពោះទ្រព្យធានាដែលអាចទទួលយកបាន ដោយផ្អែកលើហានិភ័យសំខាន់ៗមួយចំនួន ដូចជា ហានិភ័យឥណទាន ហានិភ័យសន្ទនីយភាព ហានិភ័យទីផ្សារ និងហានិភ័យប្រតិបត្តិការ។

**ប្រការ ៩.- លក្ខខណ្ឌក្នុងកិច្ចសន្យាស្ដីពី ការផ្ដល់សន្ទនីយភាពចាំបាច់**

គ្រឹះស្ថានដែលទទួលបានសន្ទនីយភាពចាំបាច់ ត្រូវ៖

១/- ផ្អាកការបែងចែកភាគលាភ និងការទិញភាគហ៊ុនត្រឡប់មកវិញ

២/- ព្យួរការដំឡើងប្រាក់បៀវត្សរ៍ និងប្រាក់រង្វាន់របស់សមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់

៣/- ផ្អាកការវិនិយោគថ្មី និង

៤/- ផ្អាកការសងត្រឡប់ទៅភាគទុនិក និងសម្ព័ន្ធញាតិ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានអនុវត្តតាមលក្ខខណ្ឌផ្សេងទៀត ដែលពាក់ព័ន្ធនឹងការផ្ដល់សន្ទនីយភាពចាំបាច់ ដូចខាងក្រោម៖

១/- វិធានការកម្រិតការផ្ដល់ឥណទានថ្មី

២/- ការលក់ទ្រព្យសកម្មដែលមិនមែនជាទ្រព្យសកម្មស្នូល

៣/- វិធានការស្ដារស្ថិរភាពប្រាក់បញ្ញើ

៤/- វិធានការពង្រឹងភាពគ្រប់គ្រាន់នៃដើមទុន (ដូចជា ការបង្កើនដើមទុន) និង/ឬ

៥/- ការត្រួតពិនិត្យគុណភាពទ្រព្យសកម្ម និង/ឬ ការធ្វើសវនកម្មពីភ្នាក់ងារឯករាជ្យខាងក្រៅ ដោយភ្ជាប់ជាមួយរបាយការណ៍លទ្ធផលមកធនាគារជាតិនៃកម្ពុជា។

**ប្រការ ១០.- ភាតព្វកិច្ចរាយការណ៍**

ក្រោយពេលទទួលបានសន្ទនីយភាពចាំបាច់ គ្រឹះស្ថានត្រូវផ្ដល់ជូនធនាគារជាតិនៃកម្ពុជា ជាប្រចាំថ្ងៃនូវរបាយការណ៍លំហូរសាច់ប្រាក់ចេញ-ចូល។ លើសពីនេះ គ្រឹះស្ថានត្រូវផ្ដល់របាយការណ៍វឌ្ឍនភាពមកធនាគារជាតិនៃកម្ពុជា រៀងរាល់ ១៤ (ដប់បួន) ថ្ងៃម្ដង ឬញឹកញាប់ជាងនេះ តាមការចាំបាច់ ដោយត្រូវមានព័ត៌មានយ៉ាងតិច ដូចខាងក្រោម៖

១/- ផលប៉ះពាល់លើស្ថានភាពសន្ទនីយភាពរបស់គ្រឹះស្ថាន

២/- បញ្ហាប្រឈមក្នុងការអនុវត្តផែនការសកម្មភាព ដូចមានកំណត់ក្នុងប្រការ ៥ នៃប្រកាសនេះ

៣/- ការអនុលោមតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យាស្ដីពី ការផ្ដល់សន្ទនីយភាពចាំបាច់

៤/- ព្រឹត្តិការណ៍ដែលអាចបណ្ដាលឱ្យមានការផ្លាស់ប្ដូរចំណាត់ថ្នាក់នៃទ្រព្យធានា ដោយត្រូវផ្ដល់នូវឯកសារគាំទ្រពាក់ព័ន្ធចាំបាច់ ប្រសិនបើមាន និង

៥/- របាយការណ៍ព្យាករលំហូរសន្ទនីយភាពសុទ្ធសម្រាប់រយៈពេល ១៤ (ដប់បួន) ថ្ងៃខាងមុខ។

បន្ទាប់ពីទទួលបានសន្ទនីយភាពចាំបាច់ គ្រឹះស្ថានត្រូវធ្វើបច្ចុប្បន្នភាពនិងផ្ញើជូនធនាគារជាតិនៃកម្ពុជានូវផែនការទុនជាប្រចាំរៀងរាល់ ៣ (បី) ខែម្ដង ឬញឹកញាប់ជាងនេះ ក្នុងករណីការព្យាករនៅក្នុងផែនការទុនមុនមានការប្រែប្រួលខ្លាំង។

ធនាគារជាតិនៃកម្ពុជាអាចតម្រូវឱ្យគ្រឹះស្ថានរៀបចំរបាយការណ៍ផ្សេងទៀតតាមការចាំបាច់។

**ប្រការ ១១.- ការរក្សាការសម្ងាត់**

ដំណើរការនៃការស្នើសុំ និងការអនុម័តសន្ទនីយភាពចាំបាច់ ត្រូវចាត់ទុកជាការសម្ងាត់។

ភាគទុនិក ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ និងរាល់បុគ្គលិករបស់គ្រឹះស្ថាន និងបុគ្គលដទៃទៀតដែលធ្វើការពាក់ព័ន្ធ ឬបានដឹងឮពីការដាក់ពាក្យស្នើសុំសន្ទនីយភាពចាំបាច់ មិនត្រូវបញ្ចេញព័ត៌មានស្តីពីការស្នើសុំនេះ ទៅភាគីណាមួយ ឬជាសាធារណៈបានឡើយ។

ក្នុងករណីមិនគោរពតាមកាតព្វកិច្ចរក្សាការសម្ងាត់នេះ ពាក្យស្នើសុំនេះនឹងត្រូវចាត់ទុកជាមោឃៈ ហើយគ្រឹះស្ថាននឹងត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ១២.- និរាករណ៍**

ប្រកាសលេខ ធ៧-០១៥-១៥៣ ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ស្តីពី ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៣.- ការអនុវត្ត**

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ អគ្គនាយកប្រតិបត្តិការ អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គបេឡា អគ្គនាយកគ្រប់គ្រងសាច់ប្រាក់ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១៤.- ប្រសិទ្ធភាពអនុវត្ត**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ២កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០២៦

**ទេសាភិបាល**

**ជា សិរី**

**__កន្លែងទទួល៖__**

- ដូចប្រការ ១៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**__ចម្លងជូន៖__**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"